# ព្រឹត្តិបត្រព័ត៌មាន NEC BULLETIN គ.ជ.ប

លេខ ២ ចេញផ្សាយថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១

## ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១១

**ឃុំ សង្កាត់ចំនួន ៣៦៧ ដែលរងគ្រោះដោយទឹកជំនន់ត្រូវបានបន្ថែមពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**



## ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានសារៈសំខាន់



ឃុំព្រះប្រសប់ ខេត្តកណ្ដាល

មាតិកា


- ឃុំ សង្កាត់ចំនួន ៣៦៧ ដែលរងគ្រោះដោយទឹកជំនន់ត្រូវបានបន្ថែមពេល..........ទំព័រទី ២
- ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមានសារៈសំខាន់........................................ទំព័រទី ៥
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបង្កលក្ខណៈងាយស្រួល....................ទំព័រទី ៦
- បណ្ណាល័យរូបភាពស្ដីពីសកម្មភាពការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត.ទំព័រទី ៨
- ការប្ដឹងតវ៉ា និងដោះស្រាយបណ្ដឹង...........................................................ទំព័រទី ១០
- លោក នឹម វ៉ាន់សំ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តសៀមរាប..ទំព័រទី ១៣


necinfo@forum.org.kh www.necelect.org.kh Fax/Phone: (023) 214 374, 214231, Tel: 012 855 018





# ឃុំ សង្កាត់ចំនួន ៣៦៧ ដែលរងគ្រោះដោយទឹកជំនន់ត្រូវបានបន្ថែមរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានសម្រេចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចំនួន**៣**ថ្ងៃសម្រាប់ឃុំ សង្កាត់ចំនួន**៣៦៧**នៅក្នុងរាជធានី ខេត្តចំនួន**១៦**ដែលរងគ្រោះដោយទឹកជំនន់។

រាជធានី ខេត្តដែលមានឃុំ សង្កាត់ត្រូវបន្ថែមរយៈពេលសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរួមមាន ÷

-**ខេត្តបន្ទាយមានជ័យ** មានឃុំចំនួន**៥** គឺឃុំគោកបល្ល័ង្គ ឃុំសំបួរ ឃុំប្រាសាទ ឃុំតាគង់ និងឃុំទឹកជោរ។

-**ខេត្តបាត់ដំបង** មានឃុំ សង្កាត់ចំនួន**១៩** គឺឃុំព្រៃត្រឡាច ឃុំដូនបា ឃុំតាសែន សង្កាត់វត្តគរ សង្កាត់ស្វាយប៉ោ ឃុំសំរោងក្នុង ឃុំព្រែកហ្លួង ឃុំព្រែកខ្ពប ឃុំឫស្សីក្រាំង ឃុំជ្រៃ ឃុំតាលាស់ ឃុំកកោះ ឃុំល្វា ឃុំព្រៃតូច និងឃុំកន្ទឺ១។

-**ខេត្តកំពង់ចាម** មានឃុំចំនួន**៥៦** គឺឃុំបាធាយ ឃុំច្បារអំពៅ ឃុំសណ្តែក ឃុំតាំងក្រសាំង ឃុំត្រប់ ឃុំគគរ ឃុំកោះមិត្ត ឃុំកោះរកា ឃុំកោះសំរោង ឃុំកោះទន្ទឹម ឃុំអង្គរបាន ឃុំកងតាណឹង ឃុំខ្ចៅ ឃុំពាមជីកង ឃុំព្រែកកុយ ឃុំព្រែកក្របៅ ឃុំរាយប៉ាយ ឃុំរកាអារ ឃុំរកាគយ ឃុំស្ដៅ ឃុំស្វាគង ឃុំកំពង់រាប ឃុំកោះសូទិន ឃុំល្វេ ឃុំមហាលាភ ឃុំមហាខ្ញូង ឃុំពាមប្រធ្នោះ ឃុំពង្រ ឃុំព្រែកតានង់ ឃុំជ្រៃទីក ឃុំកំពង់ទ្រាល ឃុំកោះពីរ ឃុំក្រូចឆ្មារ ឃុំប៉ុស១ ឃុំប៉ុស២ ឃុំព្រែកអាជី ឃុំរកាខ្នុរ ឃុំស្វាយឃ្លាំង ឃុំទ្រា ឃុំបារាយណ៍ ឃុំកោះអណ្តែត ឃុំមានជ័យ ឃុំព្រែកដំបូក ឃុំព្រែកពោធិ៍ ឃុំព្រែករំដេង ឃុំដងក្ដារ ឃុំខ្ពបតាងួន ឃុំពាមកោះស្នា ឃុំព្រះអណ្តូង ឃុំព្រែកបាក់ ឃុំព្រែកកក់ ឃុំទួលសំបួរ ឃុំបឹងព្រួល ឃុំជីរោទិ៍១ ឃុំពាមជីលាំង និងឃុំទន្លេបិទ។

-**ខេត្តកំពង់ឆ្នាំង** មានឃុំ សង្កាត់ចំនួន**៣៣** គឺឃុំឆ្នុកទ្រូ ឃុំចក ឃុំខុនរ៉ង ឃុំកំពង់ព្រះគគីរ ឃុំមេលំ ឃុំផ្សារ ឃុំពន្លៃ ឃុំត្រពាំងចាន់ ឃុំជលសា ឃុំកោះថ្កូវ ឃុំកំពង់អុស ឃុំពាមឆ្កោក ឃុំព្រៃគ្រី សង្កាត់ផ្សារឆ្នាំង សង្កាត់កំពង់ឆ្នាំង សង្កាត់ខ្សាម ឃុំកំពង់ហៅ ឃុំផ្លូវទូក ឃុំពោធិ៍ ឃុំប្រឡាយមាស ឃុំសំរោងសែន ឃុំស្វាយរំពារ ឃុំអំពិលទឹក ឃុំច្រេស ឃុំកំពង់ត្រឡាច ឃុំលង្វែក ឃុំសែប ឃុំតាជេស ឃុំអណ្តូងស្នាយ ឃុំជ្រៃបាក់ ឃុំគោកបន្ទាយ ឃុំស្វាយជ្រុំ និងឃុំទឹកហូត។

-**ខេត្តកំពង់ធំ** មានឃុំ សង្កាត់ចំនួន**៧១** គឺឃុំបាក់ស្នា ឃុំបល្ល័ង្គ ឃុំបារាយណ៍ ឃុំបឹង ឃុំចើងដើង ឃុំឈូកខ្សាច់ ឃុំចុងដូង ឃុំគគីរធំ ឃុំក្រវ៉ា ឃុំពង្រ ឃុំស្វយោង ឃុំស្រឡៅ ឃុំត្នោតជុំ ឃុំទ្រៀល ឃុំជ័យ ឃុំដីរស្លាប់ ឃុំកំពង់គោ ឃុំកំពង់ស្វាយ ឃុំនីពេជ ឃុំផាត់សណ្ដាយ ឃុំសាន់គ ឃុំត្បែង ឃុំត្រពាំងឫស្សី ឃុំក្ដីដូង ឃុំព្រៃគុយ សង្កាត់ដំរីជាន់ខ្លា សង្កាត់កំពង់ធំ សង្កាត់កំពង់រទេះ សង្កាត់អូរកន្ធរ សង្កាត់កំពង់ក្របៅ សង្កាត់ព្រៃតាហ៊ូ



សង្កាត់អាចារ្យលាក់ សង្កាត់ស្រយ៉ូវ ឃុំដូង ឃុំក្រយា ឃុំផាន់ញើម ឃុំសាគ្រាម ឃុំសាមគ្គី ឃុំឈូក ឃុំគោល ឃុំសំបូរណ៍ ឃុំស្រើង ឃុំតាំងក្រសៅ ឃុំឈើទាល ឃុំដងកាំបិត ឃុំក្លែង ឃុំមានរិទ្ធ ឃុំមានជ័យ ឃុំងន ឃុំសណ្ដាន់ ឃុំត្បូងក្រពើ ឃុំបឹងល្វា ឃុំជ្រាប់ ឃុំកំពង់ថ្ម ឃុំកកោះ ឃុំក្រយា ឃុំព្នៅ ឃុំប្រាសាទ ឃុំតាំងក្រសាំង ឃុំទីពោ ឃុំបន្ទាយស្ទោង ឃុំចំណាក្រោម ឃុំចំណាលើ ឃុំកំពង់ចិនជើង ឃុំម្សាក្រង ឃុំពពក ឃុំប្រឡាយ ឃុំព្រះដំរី ឃុំរុងរឿង ឃុំសំព្រោច និងឃុំទ្រា។



*ទឹកជំនន់ជន់លិចនៅឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល*

-**ខេត្តកណ្ដាល** មានឃុំចំនួន**៣១** គឺឃុំព្រែកឫស្សី ឃុំកោះរះ ឃុំសារិកាកែវ ឃុំព្រែកក្មេង ឃុំអរិយក្សត្រ ឃុំពុកឫស្សី ឃុំលើកដែក ឃុំប្រាសាទ ឃុំវិហារសួគ៌ ឃុំស្វាយជ្រុំ ឃុំព្រែកតាកូវ ឃុំព្រែកអំពិល ឃុំព្រះប្រសប់ ឃុំបារ៉ុង ឃុំព្រែករៃ ឃុំថ្មគរ ឃុំទឹកឃ្លាំង ឃុំពាមឧកញ៉ាអុង ឃុំកោះអន្លង់ចិន ឃុំកោះខ្សាច់ទន្លា ឃុំបាក់ដាវ ឃុំជ័យធំ ឃុំស្វាយរមៀត ឃុំកំពង់ភ្នំ ឃុំក្អមសំណរ ឃុំព្រែកទន្លាប់ ឃុំសណ្ដារ ឃុំកំពង់អុស ឃុំកោះចិន ឃុំស្វាយប្រទាល និងឃុំត្រើយស្លា។

-**ខេត្តក្រចេះ** មានឃុំ សង្កាត់ចំនួន**១៥** គឺឃុំឆ្លូង ឃុំដំរីផុង ឃុំកញ្ជរ ឃុំខ្សាច់អណ្ដែត ឃុំពង្រ ឃុំព្រែកសាម៉ាន់ ឃុំបុសលាវ ឃុំកោះច្រែង សង្កាត់ក្រចេះ ឃុំជ្រោយបន្ទាយ ឃុំកំពង់គរ ឃុំព្រែកប្រសព្វ ឃុំសោប ឃុំតាម៉ៅ និងឃុំកំពង់ចាម។

-**រាជធានីភ្នំពេញ** មានសង្កាត់ចំនួន**១២** គឺសង្កាត់និរោធ សង្កាត់ក្បាលកោះ សង្កាត់ព្រែកឯង សង្កាត់ព្រែកថ្មី សង្កាត់វាលស្បូវ សង្កាត់ព្រែកតាសេក សង្កាត់ជ្រោយចង្វា សង្កាត់បាក់ខែង សង្កាត់កោះដាច់ សង្កាត់ពញាពន់ សង្កាត់ព្រែកព្នៅ និងសង្កាត់សំរោង។

-**ខេត្តព្រះវិហារ** មានឃុំ សង្កាត់ចំនួន**៣១** គឺឃុំពុទ្រា ឃុំឆែបពីរ ឃុំម្លូព្រៃមួយ ឃុំម្លូព្រៃពីរ ឃុំកំពង់ស្រឡៅមួយ ឃុំកំពង់ស្រឡៅពីរ ឃុំជាំក្សាន្ត ឃុំទឹកក្រហម ឃុំព្រីងធំ ឃុំរំដោះស្រែ ឃុំយាង ឃុំកន្ទួត ឃុំគូលែនត្បូង ឃុំគូលែនជើង ឃុំថ្មី ឃុំភ្នំពេញ ឃុំភ្នំត្បែងពីរ ឃុំស្រយង់ ឃុំរួសរាន់ ឃុំរតនៈ ឃុំរៀបរយ ឃុំរក្សា ឃុំរអាង ឃុំស្ដៅ ឃុំរណសិរ្ស សង្កាត់កំពង់ប្រណាក សង្កាត់ប៉ាលហាល ឃុំឈានមុខ ឃុំពោធិ៍ ឃុំប្រមេរុ និងឃុំព្រះឃ្លាំង។

-**ខេត្តព្រៃវែង** មានឃុំចំនួន**៤២** គឺឃុំអង្គរអង្គ ឃុំកំពង់ប្រាសាទ ឃុំកោះចេក ឃុំកោះរកា ឃុំកោះសំពៅ ឃុំក្រាំងតាយ៉ង ឃុំព្រែកក្របៅ ឃុំព្រែកសំបួរ ឃុំឫស្សីស្រុក ឃុំស្វាយភ្លោះ ឃុំកំពង់ពពិល ឃុំកញ្ជំ ឃុំកំពង់ប្រាំង ឃុំមេសរប្រចាន់ ឃុំព្រៃព្នៅ ឃុំព្រៃស្នៀត ឃុំព្រៃស្រឡិត ឃុំរាប ឃុំរកា ឃុំពោធិ៍រៀង ឃុំព្រែកអន្ទះ ឃុំព្រែកជ្រៃ ឃុំព្រែកខ្លោង ឃុំតាកោ ឃុំកពង់ឫស្សី ឃុំព្រែកតាសរ ឃុំអំពិលក្រៅ ឃុំជ្រៃឃ្មុំ ឃុំល្វេ ឃុំព្នៅទី១ ឃុំព្នៅទី២ ឃុំពោធិទី ឃុំព្រែកចង្ក្រាន ឃុំព្រៃដើមថ្នឹង ឃុំព្រៃទឹង ឃុំរំលេច ឃុំឫស្សីសាញ់ ឃុំពាមមន្ទារ



# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

ឃុំបន្ទិចប្រាសាទ ឃុំពាមមានជ័យ ឃុំបឹងដោល និងឃុំរាធរ។

-**ខេត្តពោធិ៍សាត់** មានឃុំ សង្កាត់ចំនួន**១៥** គឺឃុំស្វាយដូនកែវ ឃុំអូរតាប៉ោង ឃុំមេទឹក ឃុំបឹងបត់កណ្តាល ឃុំស្នាមព្រះ ឃុំស្យា ឃុំកញ្ជរ ឃុំស្រែស្ដុក ឃុំអន្សាចំបក់ ឃុំក្បាលត្រាច ឃុំស្នាអន្សា ឃុំអូរសណ្តាន់ ឃុំរាំងទិល ឃុំកំពង់លួង និងឃុំកំពង់ពោធិ៍។

-**ខេត្តសៀមរាប** មានឃុំ សង្កាត់ចំនួន**៨** គឺឃុំពង្រលើ សង្កាត់សាលាកំរើក សង្កាត់ជ្រាវ សង្កាត់សៀមរាប ឃុំស្រែណូយ ឃុំរ៉ារិន ឃុំក្រឡាញ់ និងឃុំក្រូចគរ។

-**ខេត្តតាកែវ** មានឃុំចំនួន**១៥** គឺឃុំអង្គរបូរី ឃុំគោកធ្លក ឃុំពន្លៃ ឃុំព្រែកផ្ទោល ឃុំព្រៃផ្តៅ ឃុំកំណប់ ឃុំក្រពុំឈូក ឃុំព្រៃខ្លា ឃុំព្រៃយុថ្កា ឃុំកំពង់រាប ឃុំបូរីជលសារ ឃុំជ័យជោគ ឃុំដូងខ្ពស់ ឃុំកពង់ក្រសាំង និងឃុំគោកពោធិ៍។

-**ខេត្តកែប** មានឃុំ សង្កាត់ចំនួន**៣** គឺឃុំពងទឹក សង្កាត់អូរក្រសារ និងសង្កាត់ព្រៃធំ។

-**ខេត្តប៉ៃលិន** មានឃុំ សង្កាត់ចំនួន**៣** គឺសង្កាត់ប៉ៃលិន ឃុំស្ទឹងត្រង់ និងឃុំស្ទឹងកាច់។

-**ខេត្តឧត្តរមានជ័យ** មានឃុំ សង្កាត់ចំនួន**១២** គឺឃុំអន្លង់វែង ឃុំត្រពាំងប្រីយ៍ ឃុំត្រពាំងតាវ ឃុំបេង ឃុំគោកខ្ពស់ ឃុំក្រសាំង សង្កាត់បុស្សស្បូវ សង្កាត់កូនក្រៀល សង្កាត់សំរោង ឃុំបាក់អន្លូង ឃុំអូរស្វាយ និងឃុំត្រពាំងប្រសាទ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា ការពន្យារពេលនេះធ្វើឡើងបន្ទាប់ពីមានរបាយការណ៍ស្នើសុំរបស់លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធ និងតាមរយៈកិច្ចប្រជុំជាមួយគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិ



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

បាលដែលធ្វើឡើងកាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១។

លោក ណៃ ឃី មេឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះបានមានប្រសាសន៍កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១នេះថា ឃុំបុសលាវមាន៨ភូមិត្រូវបានជន់លិចទាំងស្រុងដោយទឹកជំនន់ដែលធ្វើឱ្យលោកពិបាករកទីទួល



លោក ណៃ ឃី មេឃុំបុសលាវពេលផ្តល់បទសម្ភាសន៍ដល់អ្នកយកព័ត៌មាន គ.ជ.ប

ខ្ពស់នៅពេលការិយាល័យចុះឈ្មោះបោះឆ្នោតចល័តពីសាលាឃុំទៅតាមភូមិ ប៉ុន្តែលោកបានខិតខំរិះរកទីទួលមានសុវត្ថិភាពណាមួយសម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងការមកពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដ៏មានសារៈសំខាន់នេះ។ លោកបានបន្តថា ឃុំបុសលាវទទួលបានរយៈពេលបន្ថែម៣ថ្ងៃពី គ.ជ.ប សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត៕



# ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមានសារៈសំខាន់

ការងារបោះឆ្នោតគឺជាការងារមានសារៈសំខាន់ និងចាំបាច់បំផុតនាសម័យបច្ចុប្បន្ននេះ។ ព្រោះថាប្រជាពលរដ្ឋអាចជ្រើសរើសមេដឹកនាំណាដែលខ្លួនយល់ថាអាចជួយដោះស្រាយនូវទុក្ខកង្វល់ ការលំបាក និងដឹកនាំប្រទេសឱ្យមានការរីកចំរើនប្រកបដោយសុខសន្តិភាពតាមរយៈការបោះឆ្នោតនេះ។

ដើម្បីបោះឆ្នោតជ្រើសរើសមេដឹកនាំដែលខ្លួនពេញចិត្តទាល់តែមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលាឆ្នាំ២០១១។ នៅក្នុងអំឡុងពេលនេះ ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង (អ្នកគ្រប់អាយុបោះឆ្នោត) អ្នកមិនធ្លាប់បានចុះឈ្មោះបោះឆ្នោត អ្នកផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ថ្មី ត្រូវទៅចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ឬទីកន្លែងណាមួយតាមការជូនដំណឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយអ្នកដែលធ្លាប់បានចុះឈ្មោះរួច ត្រូវទៅពិនិត្យមើលឈ្មោះរបស់ខ្លួនដើម្បីឱ្យប្រាកដថា ពិតជាមានឈ្មោះត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ។ ប្រជាពលរដ្ឋដែលមកចុះឈ្មោះបោះឆ្នោតត្រូវយកឯកសារទៅជាមួយរួមមាន ៖

១-ឯកសារបញ្ជាក់អត្តសញ្ញាណ
២-ឯកសារបញ្ជាក់ពីសញ្ជាតិ
៣-ឯកសារបញ្ជាក់ទីលំនៅ
៤-ឯកសារបញ្ជាក់អាយុ១៨ឆ្នាំ

តទៅទំព័រទី 15



លោក សួស សារិន ចៅសង្កាត់បឹងទំពុនពេលផ្តល់បទសម្ភាសន៍ដល់អ្នកយកព័ត៌មាន គ.ជ.ប





ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់បឹងទំពុន





# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្កលក្ខណៈងាយស្រួលឱ្យ កម្មករ និយោជិតទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

សម្រាប់ឆ្នាំនេះ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមានរយៈពេល៤៥ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី១ខែកញ្ញា រហូតដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១។ ដើម្បីបោះឆ្នោតបាន បងប្អូនប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនក្នុងពេលបោះឆ្នោត។



ជាមួយគ្នានេះកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានអំពាវនាវដល់ស្ថាប័នជាតិនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ គណបក្សនយោបាយ សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល រោងចក្រ សហគ្រាស ក្រុមហ៊ុន សូមបង្កលក្ខណៈល្អ និងជម្រុញលើកទឹកចិត្តដល់មន្ត្រីរាជការ បុគ្គលិកកម្មករក្រោមឱវាទក៏ដូចជាប្រជាពលរដ្ឋទាំងអស់ឱ្យទៅពិនិត្យមើលបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា និងទាន់ពេលវេលា។



*កញ្ញា រស់ វណ្ណារី កម្មការិនីរោងចក្រ M&V3*

កញ្ញា រស់ វណ្ណារី អាយុ២៥ឆ្នាំជាកម្មការិនីបម្រើការងារនៅរោងចក្រ M&V3 ដែលមានទីតាំងនៅសង្កាត់ចាក់អង្រែក្រោមបានឱ្យដឹងថា កញ្ញាមានភូមិកំណើតនៅសង្កាត់ក្បាលកោះ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ កញ្ញាធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ។ ទាក់ទងទៅនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត កញ្ញបានឱ្យដឹងថា ខាងរោងចក្របានអនុញ្ញាតឱ្យឈប់សម្រាកចំនួន៥ថ្ងៃគឺ៣ថ្ងៃសម្រាប់បុណ្យភ្ជុំបិណ្ឌ និង២ថ្ងៃសម្រាប់ទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ វណ្ណារីបានបន្ថែមថា ទោះបីឃុំក្បាលកោះរងនូវទឹកជំនន់ក៏ដោយ ក៏កញ្ញាបានទៅពិនិត្យបញ្ជីឈ្មោះរួចហើយដែរ ហើយនឹងចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ខាងមុខនេះ ព្រោះថាសន្លឹកឆ្នោតមួយសន្លឹកអាចឱ្យភូមិឃុំមានសន្តិភាព និងការអភិវឌ្ឍ។

# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១





*កញ្ញា យន់ ស្រីអូន កម្មការិនីរោងចក្រ M&V3*

រីឯកញ្ញា យន់ ស្រីអូន អាយុ២៣ឆ្នាំ មានស្រុកកំណើតនៅភូមិរាំងឫស្សី ឃុំព្រៃស្វាយ ស្រុកសង្កែ ខេត្តបាត់ដំបង ហើយជាកម្មការិនីបម្រើការងារនៅរោងចក្រ M&V3 ដែរនោះ បាននិយាយថា នាយករោងចក្របានអនុញ្ញាតច្បាប់ឱ្យកញ្ញាឈប់សម្រាកចំនួន៣ថ្ងៃបន្ទាប់ពីការឈប់សម្រាកបុណ្យភ្ជុំបិណ្ឌកន្លងមកដើម្បីទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ រោងចក្រមិនបានកាត់ប្រាក់ឧបត្ថម្ភ ឬប្រាក់រង្វាន់នោះទេ ថែមទាំងបានបើកប្រាក់បៀវត្សជូនកញ្ញាមុនថ្ងៃបុណ្យភ្ជុំបិណ្ឌទៀតផង។ កញ្ញាបានបន្តទៀតថា កញ្ញាធ្លាប់បានចុះឈ្មោះម្តងហើយ ហើយក៏បានទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ឆ្នាំ២០០៨ផងដែរ។

ដើម្បីឱ្យកម្មករ និយោជិតបានឈប់សម្រាក និងចូលរួមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីជូនដំណឹងលេខ១៦៩កប/ស.ជ.ណចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ណែនាំដល់ម្ចាស់ និងនាយកសហគ្រាសគ្រឹះស្ថានទាំងអស់អនុញ្ញាតឱ្យកម្មករ និយោជិតបានឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌចំនួន៣ថ្ងៃគឺថ្ងៃទី២៦_២៨ ខែកញ្ញា ឆ្នាំ២០១១ និងអនុញ្ញាតឱ្យកម្មករ និយោជិតទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមកាលបរិច្ឆេទ និងទីកន្លែងដូចខាងក្រោម ៖

**ក**_កម្មករ និយោជិតធ្វើការនៅរាជធានីភ្នំពេញ_ខេត្តត្រូវទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅរាជធានីភ្នំពេញ_ខេត្តនោះផ្ទាល់**នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១១។**

**ខ**_កម្មករ និយោជិតធ្វើការនៅរាជធានីភ្នំពេញត្រូវទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅខេត្តកណ្តាលកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម ព្រៃវែង ស្វាយរៀង កំពង់ធំ តាកែវ កំពត កែប និងខេត្តព្រះសីហនុ ត្រូវឈប់សម្រាកនៅ**ថ្ងៃទី២៩_៣០ ខែកញ្ញា ឆ្នាំ២០១១។**

**គ**_កម្មករ និយោជិតធ្វើការនៅរាជធានីភ្នំពេញត្រូវទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតខេត្តផ្សេងក្រៅពីខេត្តដែលបានរៀបរាប់ខាងលើនេះ ត្រូវឈប់សម្រាកនៅ**ថ្ងៃទី២៩_៣០ ខែកញ្ញា ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១។**



តទៅទំព័រទី 14

# សកម្មភាពពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅ





សកម្មភាពការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅខេត្តកំពង់ចាម





សកម្មភាពការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ





សកម្មភាពការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំបុសលាវ ខេត្តក្រចេះ



# តាមបណ្ដាឃុំ សង្កាត់ក្នុងរាជធានី និងខេត្តមួយចំនួន





សកម្មភាពការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅខេត្តមណ្ឌលគិរី





សកម្មភាពការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅសាលារៀនចំរើនផល ក្នុងសង្កាត់បឹងទំពុន រាជធានីភ្នំពេញ





សកម្មភាពការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំក្តឿងរាយ ខេត្តព្រៃវែង

# ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹង និងការចុះឈ្មោះតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត



*លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប*

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) តែងតែផ្សព្វផ្សាយទូលាយនូវរាល់ព័ត៌មានទាក់ទងនឹងការបោះឆ្នោតតាមរយៈកិច្ចប្រជុំប្រចាំខែ ការផលិតសម្ភារអប់រំផ្សព្វផ្សាយដូចជាស្ប៉ូតវិទ្យុ ស្ប៉ូតវីដេអូ Poster បដា ពាក្យស្លោក ផ្សាយមេក្រូចល័តដើម្បីលើកទឹកចិត្តអ្នកដែលបានចុះឈ្មោះបោះឆ្នោត អ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោត អ្នកទើបគ្រប់អាយុបោះឆ្នោត អ្នកផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ថ្មី ឱ្យទៅពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងជម្រុញឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបយល់ដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការចូលរួមបោះឆ្នោតជ្រើសរើសអ្នកដឹកនាំនៅថ្នាក់ឃុំ សង្កាត់ តាមរយៈការបោះឆ្នោតបែបលទ្ធិប្រជាធិបតេយ្យដោយសេរី សម្ងាត់ ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។ ជាពិសេសតាមរយៈកម្មវិធីស្វែងយល់ពីការបោះឆ្នោត ដែលកម្មវិធីនេះបានអញ្ជើញថ្នាក់ដឹកនាំ គ.ជ.ប ដើម្បីធ្វើការផ្សព្វផ្សាយពីការរៀបចំ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត។ ជាមួយគ្នានេះដែរ កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប បានអញ្ជើញចូលរួមក្នុងកម្មវិធីនេះ ដើម្បីបកស្រាយអំពីការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹង និងការចុះឈ្មោះតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១។ បទសម្ភាសន៍នេះត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា ហើយព្រឹត្តិបត្រព័ត៌មាន គ.ជ.ប សូមធ្វើការដកស្រង់ និងចុះផ្សាយខ្លឹមសារទាំងនេះដូចខាងក្រោម ៖

**សំណួរ ៖ មុននឹងចូលទៅដល់សំណួរអំពីបណ្តឹង ខ្ញុំសូមលោកជំទាវបណ្ឌិតមានប្រសាសន៍បន្តិចពីវិសោធនកម្មច្បាប់ដែលទាក់ទងទៅនឹងបណ្តឹងនៅពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១នេះ?**

**ចម្លើយ ៖** ជាបឋមខ្ញុំសូមគោរពដល់ទូរទស្សនិកជនទាំងអស់ដែលតាមដានកម្មវិធីស្វែងយល់អំពីការបោះឆ្នោត។ ឆ្លៀតឱកាសនេះខ្ញុំសូមអនុញ្ញាតជម្រាបជូន ៖

ទី១-អំពីវិសោធនកម្មច្បាប់បោះឆ្នោត រយៈពេលនៃការដាក់ពាក្យ និងដោះស្រាយបណ្តឹង និងដាក់ពាក្យសុំសង្កេតការណ៍ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

ទី២-ខ្ញុំសូមជម្រាបជូនអំពីមតិជុំវិញសមាសភាពរបស់ គ.ជ.ប។



ថ្មីៗនេះ រដ្ឋសភាបានអនុម័តវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើ១៣មាត្រា ប៉ុន្តែមាត្រាសំខាន់ទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះមានតែ២មាត្រាទេ។

១_មាត្រា ៤៩ ថ្មី (បី) ៖

_គឺការផ្តល់សិទ្ធិដល់ គ.ជ.ប ក្នុងការបន្ថែមរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរហូតដល់ទៅ៣០ថ្ងៃសម្រាប់ឆ្នាំដែលមានការបោះឆ្នោតសកល(មុនវិសោធនកម្មយើងមានតែ១៥ថ្ងៃទេ)។ ដូច្នេះ ដោយសារឆ្នាំក្រោយមានការបោះឆ្នោតសកលជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ហើយបញ្ជីបោះឆ្នោតដែលយើងធ្វើបច្ចុប្បន្នភាពឆ្នាំនេះ ក៏សម្រាប់ប្រើក្នុងការបោះឆ្នោតឆ្នាំក្រោយផងដែរ ហេតុនេះហើយទើបការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជាក់ស្តែងនៅឃុំ សង្កាត់គឺមានរយៈពេល៤៥ថ្ងៃ ខុសប្លែកពីឆ្នាំមុនៗ។

_ក្រៅពីនេះ វិសោធនកម្មក៏បានផ្តល់សិទ្ធិដល់ គ.ជ.ប ក្នុងការរៀបចំបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់បង្កើតថ្មី ឬកែប្រែព្រំប្រទល់រដ្ឋបាលផងដែរ។

២_មាត្រា ៦៤ ថ្មី (ពីរ) ៖

_បានបន្ថែមរយៈពេលប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង គឺមានរយៈពេល១០ថ្ងៃសម្រាប់ឆ្នាំមានការរៀបចំការបោះឆ្នោតជាសកល(កាលពីមុនរយៈពេលមានតែ៥ថ្ងៃប៉ុណ្ណោះ)។

**សំណួរ ៖ បើមើលតាមប្រតិទិនក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១នេះ ពេលវេលាដាក់ពាក្យបណ្តឹង និងដោះស្រាយបណ្តឹងមានពីររយៈពេលខុសគ្នា។ សូមលោកជំទាវជួយបំភ្លឺជូនទូរទស្សនិកជនឱ្យបានជ្រាបអំពីលក្ខណៈខុសគ្នានេះផង?**

**ចម្លើយ ៖** ជាការពិតក្នុងប្រតិទិនការងារ គឺមានបណ្តឹងចែកចេញជាពីរផ្នែកមែន ៖

**ទី១** បណ្តឹងទៅនឹងការបដិសេធរបស់ស្មៀន

ចាប់ពីថ្ងៃចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត អ្នកដែលស្មៀនឃុំ សង្កាត់បដិសេធការសុំចុះឈ្មោះបោះឆ្នោតរបស់ខ្លួន គាត់មានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះមុននឹងប្តឹងទៅ គ.ជ.ប។ បណ្តឹងបែបនេះអាចប្តឹងតាំងពីថ្នាក់ក្រោម គឺក្រុមប្រឹក្សាឃុំ សង្កាត់ ហើយអាចប្តឹងបន្តទៅ គ.ជ.ប រួចបង្ហួតទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញទៀតផង។ តាមប្រតិទិនរយៈពេលប្តឹង និងដោះស្រាយបណ្តឹងចុងក្រោយគឺចាប់ពី**ថ្ងៃទី១៨ ខែតុលា រហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១១។** សរុបនៃការដាក់ពាក្យបណ្តឹង និងដោះស្រាយបណ្តឹងក្នុងផ្នែកនេះមាន៣១ថ្ងៃ។

**ទី២** បណ្តឹងទៅនឹងបញ្ជីបោះឆ្នោតដំបូង

គឺក្រោយពីបញ្ចប់នូវបណ្តឹងផ្នែកទី១ចប់សព្វគ្រប់ហើយ ទើប គ.ជ.ប បិទបញ្ជីបោះឆ្នោតដំបូងជូនប្រជាពលរដ្ឋពិនិត្យមើលម្តងទៀតមុននឹងបន្តការងារធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតផ្លូវការ។ នៅពេលបិទបញ្ជីដំបូងនេះ ជនណាក៏ដោយមានសិទ្ធិប្តឹងតវ៉ា ឬជំទាស់ទៅនឹងការបាត់ឈ្មោះរបស់ខ្លួន ឬសរសេរឈ្មោះរបស់ខ្លួនពុំត្រឹមត្រូវ ឬអ្នកដែលមិនមានសិទ្ធិបោះឆ្នោតតែមានឈ្មោះក្នុងបញ្ជីដំបូង ឬអ្នកណាម្នាក់មានឈ្មោះលើសពីមួយនៅក្នុងបញ្ជីបោះឆ្នោត។

បណ្តឹង និងការដោះស្រាយបណ្តឹងក្នុងរយៈពេល





ទី២នេះអាស្រ័យទៅនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង តាមករណីមាន ឬគ្មានបណ្តឹង។ តាមប្រតិទិនការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងគឺនៅថ្ងៃទី១៩ ខែតុលា ដល់ថ្ងៃទី២១ ខែវិច្ឆិកា ហើយរយៈពេលប្តឹង និងដោះស្រាយបណ្តឹងចុងក្រោយគឺចាប់ពីថ្ងៃទី២២ ខែវិច្ឆិកា ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១។

ដូច្នេះយោងតាមវិសោធនកម្មច្បាប់ឆ្នាំនេះ សរុបទៅបណ្តឹង និងការដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងនេះមានរយៈពេល៣៨ថ្ងៃនេះរាប់ចាប់ពីការប្តឹងតវ៉ា ឬជំទាស់នៅក្រុមប្រឹក្សាឃុំ សង្កាត់រហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញ។

**សំណួរ ៖ បើមើលតាមប្រតិទិនការងាររបស់ គ.ជ.ប ឃើញថាក្រៅពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គ.ជ.ប មានការរៀបចំការបោះឆ្នោតចំនួន៣ជាបន្តបន្ទាប់គ្នា ដូចជាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញឆ្នាំ២០១១ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ផង។ តើ គ.ជ.ប មានវិធានការយ៉ាងណាខ្លះដើម្បីជួយសម្រួលដល់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិព្រមទាំងគណបក្សនយោបាយដែលចង់ចូលរួមសង្កេតនូវព្រឹត្តិការណ៍បោះឆ្នោតទាំងអស់នេះ?**

**ចម្លើយ ៖** គ.ជ.ប ចាប់ទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងគណបក្សនយោបាយសម្រាប់ចូលរួមសង្កេតព្រឹត្តិការណ៍ទាំងនេះមានលក្ខណៈខុសគ្នាបន្តិច។ រីឯព័ត៌មានទាក់ទងនឹងរឿងនេះក៏បានផ្សព្វផ្សាយជូនគណបក្សនយោបាយ និងអង្គការនានារួចហើយដែរ។

**ទី១**-សម្រាប់អ្នកសង្កេតការណ៍ជាតិ ការដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍ត្រូវដាក់ទៅ គ.ជ.ប ចាប់ផ្តើមតាំងពីថ្ងៃទី១៧ ខែសីហា ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២។ ក្រោយពីបានទទួលការអនុញ្ញាតជាផ្លូវការពី គ.ជ.ប ហើយ អ្នកដាក់ពាក្យត្រូវបានទទួលប័ណ្ណសម្គាល់ជាអ្នកសង្កេតការណ៍ជាតិពីលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ឬពីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត។ អ្នកមានប័ណ្ណសង្កេតការណ៍មានសិទ្ធិសង្កេតមើល ៖

- ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១។
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញឆ្នាំ២០១១។
- ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ឆ្នាំ២០១២។
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២។

**ទី២**-ចំពោះអ្នកសង្កេតការណ៍អន្តរជាតិក៏ត្រូវដាក់ពាក្យសុំសង្កេតការណ៍ទៅ គ.ជ.ប ដែរ គឺចាប់ផ្តើមពីថ្ងៃទី១៧ ខែសីហា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ ហើយគេអាចសង្កេតការណ៍ដូចអ្នកសង្កេតការណ៍ជាតិដែរ។

**ទី៣**-ចំពោះគណបក្សនយោបាយខុសពីអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបន្តិច។ គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយជាមួយក្រសួងមហាផ្ទៃរួចហើយ មាន

តទៅទំព័រទី 15



# លោក នឹម វ៉ាន់សំ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តសៀមរាប ជម្រាបជូនព័ត៌មាន ទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋក្នុងខេត្តសៀមរាប

កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ លោកនឹម វ៉ាន់សំ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តសៀមរាបត្រូវបានវិទ្យុ FM ជាតិនគរភ្នំ ១០២.៩០ MHz របស់មន្ទីព័ត៌មានខេត្តសៀមរាបអញ្ជើញចូលរួមធ្វើជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ "**នាទីស្រុកយើង**"។ កម្មវិធីនេះបានបើកឱកាសឱ្យប្រជាពលរដ្ឋហៅទូរស័ព្ទចូលសួរនូវរាល់ព័ត៌មានទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដែលមានសំណួរចម្លើយដូចខាងក្រោម ៖



*លោក នឹម វ៉ាន់សំ នៅក្នុងស្ទូឌីយ៉ូវិទ្យុ FM ជាតិនគរភ្នំ១០២.៩០ MHz*

**សំណួរ : តើការចុះឈ្មោះបោះឆ្នោតនេះប្រព្រឹត្តទៅនៅកន្លែងណា ហើយនៅថ្ងៃណាខែណាឆ្នាំណា?**

**ចម្លើយ** : ការចុះឈ្មោះបោះឆ្នោតនេះប្រព្រឹត្តទៅនៅសាលាឃុំ សង្កាត់ជាចម្បង ហើយបន្ទាប់មកចល័តនៅតាមភូមិមួយចំនួន មិនគ្រប់ភូមិទេ គឺអាស្រ័យទៅតាមឃុំ សង្កាត់ជាអ្នករៀបចំប្រតិទិននៃការចុះឈ្មោះបោះឆ្នោត ហើយចុងក្រោយត្រលប់មកសាលាឃុំ សង្កាត់វិញ។ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១។

**សំណួរ : តើព្រះសង្ឃអាចទៅចុះឈ្មោះបោះឆ្នោតបានដែរឬទេ?**

**ចម្លើយ** : ព្រះសង្ឃទាំងអស់អាចទៅចុះឈ្មោះបោះឆ្នោតបានបើសិនជាព្រះអង្គពុំទាន់បានចុះឈ្មោះបោះឆ្នោត ឬព្រះអង្គគ្រប់ព្រះជន្មបោះឆ្នោត។ ក្នុងការចុះឈ្មោះនេះ ប្រសិនបើព្រះអង្គពុំមានឈ្មោះនៅក្នុងសៀវភៅគ្រួសារ ឬក៏អត់មានអត្តសញ្ញាណប័ណ្ណ ព្រះអង្គត្រូវមានឯកសារដូចជាឆាយាគណៈមហានិកាយ ឬសទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ។

**សំណួរ : អត្តសញ្ញាណប័ណ្ណខ្ញុំផុតកំណត់ តើអាចទៅចុះឈ្មោះបោះឆ្នោតបានដែរឬទេ?**

**ចម្លើយ** : មានតែអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋខ្មែរតែមួយទេដែលរដ្ឋាភិបាលបានឱ្យបន្តទុតិយតា ដូច្នេះឱ្យពន្យារពេលរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ លោកអាចយកអត្តសញ្ញាណប័ណ្ណទៅប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត ទាំងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅអាណត្តិនេះ ហើយទៅចុះឈ្មោះបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០១៣ទៀត។

**សំណួរ : ចំពោះជនដែលជាប់ពាក់ព័ន្ធនឹងតុលាការចោទប្រកាន់តែមិនទាន់កំណត់មានទោស ឬអត់ទោសនៅឡើយតែពាក់ព័ន្ធនឹងផ្លូវច្បាប់ហ្នឹង តើជននោះ**





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

**អាចចុះឈ្មោះបោះឆ្នោតបានឬអត់?**

**ចម្លើយ** : អ្នកដែលគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោត គឺថា ទី១ ជនដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ទី២ ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត និងទី៣ ជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ជនទាំងនេះមិនអាចមានសិទ្ធិចុះឈ្មោះបោះឆ្នោតបានទេ។

**សំណួរ : ចំពោះជនបរទេសស្នាក់នៅស្រុកខ្មែររយៈពេលប៉ុន្មានឆ្នាំទើបមានសិទ្ធិចុះឈ្មោះ និងបោះឆ្នោត?**

**ចម្លើយ** : ច្បាប់បានកំណត់ថា មិនមានការចុះឈ្មោះឱ្យជនបរទេសទេ ទោះនៅប៉ុន្មានឆ្នាំក៏មិនមានការចុះឈ្មោះឱ្យជនបរទេសដែរ។ ការចុះឈ្មោះនេះមានលក្ខខណ្ឌ៤យ៉ាង ទី១ ឯកសារបញ្ជាក់អត្តសញ្ញាណ ទី២ឯកសារបញ្ជាក់ពីសញ្ជាតិខ្មែរ ទី៣ ឯកសារបញ្ជាក់អាយុ១៨ឆ្នាំដែលគិតដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ និងទី៤ ឯកសារបញ្ជាក់ទីលំនៅ អញ្ចឹងយើងឃើញថា បើមិនមានសញ្ជាតិជាខ្មែរយើងមិនអាចចុះឈ្មោះបោះឆ្នោតជូនគាត់បានទេ។

**សំណួរ : ចំពោះប្រជាពលរដ្ឋយើងដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតហើយ តែនៅក្នុងករណីឈ្មោះ ភេទ អាយុ ទីកន្លែងកំណើត ឬក៏អ្វីផ្សេងៗខុសគ្នា តើពួកគាត់អាចកែតម្រូវបានដែរឬទេ?**

**ចម្លើយ** : ក្នុងអំឡុងនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គឺចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ បងប្អូនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតត្រូវមកពិនិត្យមើលឈ្មោះរបស់ខ្លួនដែលមានបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ចាប់ពីថ្ងៃទី៣០ ខែសីហា ឬនៅកន្លែងណាមួយក្នុងឃុំ សង្កាត់តាមការជូនដំណឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ បើសិនឃើញឈ្មោះបងប្អូនខុសចំណុចណាមួយ បងប្អូនអាចទៅជួបស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលជួយមើលការខុសត្រូវ សុំកែទិន្នន័យទាក់ទងឈ្មោះរបស់បងប្អូនខុស ហើយក្នុងការកែគេមាននីតិវិធី គេចេញកូនបង្កាន់ដៃតូចមួយឱ្យបងប្អូន បញ្ជាក់ថា បងប្អូនបានខុសកន្លែងណានៅក្នុងបញ្ជីបោះឆ្នោត។ ដូច្នេះបងប្អូនត្រូវទៅទាក់ទងស្មៀនឃុំ សង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីកែឈ្មោះបងប្អូនដែលខុស ហើយការកែនេះមាននីតិវិធីច្បាស់លាស់ណាស់៕

តមកពីទំព័រទី 7 ***ក្រសួងការងារ និងបណ្តុះបណ្តាល...***

ចំពោះសហគ្រាសគ្រឹះស្ថានដែលមានទីតាំងក្នុងខេត្តដទៃទៀតក្រៅពីរាជធានី ភ្នំពេញនិយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករ និយោជិតតាមការកំណត់ដូចចែងក្នុងចំណុច **ខ** និង **គ** ខាងលើដែរដោយយកខេត្តនីមួយៗធ្វើជាមូលដ្ឋានដើមដូចគ្នានឹងរាជធានីភ្នំពេញដែរ។

សេចក្តីជូនដំណឹងមានខ្លឹមសារគូសបញ្ជាក់ថា រាល់ការអនុញ្ញាតច្បាប់ជូនកម្មករ និយោជិតខាងលើនេះ និយោជកត្រូវរក្សាទុកប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនកម្មករ និយោជិតដដែល។ ចំពោះកម្មករនិយោជិតដែលអវត្តមានហួសពីច្បាប់អនុញ្ញាតដែលមានចែងខាងលើនេះត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសគ្រឹះស្ថាន។ និយោជកខិតខំរៀបចំបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតឱ្យបានមុនថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ពេលវេលាទេសូមអនុញ្ញាតឱ្យកម្មករ និយោជិតទទួលប្រាក់ឈ្នួលមួយភាគជាបុរេប្រទានមុន៕



តមកពីទំព័រទី 5 **ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត...**

លោក សួស សារិន ចៅសង្កាត់បឹងទំពុនបានមានប្រសាសន៍ថា ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមានសារៈសំខាន់ណាស់ ពីព្រោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទើបយើងអាចបោះឆ្នោតបាន។ យើងជ្រើសរើសមេដឹកនាំដែលខ្លួនស្រលាញ់ពេញចិត្តតាមរយៈការបោះឆ្នោតជាសម្ងាត់នេះ។

លោកបានបន្តថា ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតជាលក្ខខណ្ឌតម្រូវមួយផងដែរសម្រាប់បេក្ខជនឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បើមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតយើងមិនអាចឈរឈ្មោះបោះឆ្នោតបានឡើយ។ លោកបានបញ្ជាក់ថា ចាប់ពីថ្ងៃទី០១ ខែកញ្ញាដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ សាលាសង្កាត់បានជូនដំណឹងដល់ប្រជាពលរដ្ឋដែលទើបគ្រប់អាយុបោះឆ្នោត អ្នកមិនបានចុះឈ្មោះបោះឆ្នោត អ្នកគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត និងអ្នកផ្លាស់ទីលំនៅចូល មកចុះឈ្មោះនៅសាលាសង្កាត់ និងទីតាំងចល័តតាមកាលកំណត់ដូចខាងក្រោម ៖

១-សាលាសង្កាត់បឹងទំពុនរយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែកញ្ញា។

២-សាលាចំរើនផលរយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា

៣-វត្តដំបូកខ្ពស់រយៈពេល៥ថ្ងៃ គឺចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៣ ខែកញ្ញា

៤-សហគមន៍ត្នោតជ្រុំ៥ ភូមិត្នោតជ្រុំ៤ រយៈពេល៥ថ្ងៃ គឺនៅថ្ងៃទី២៥-២៩-៣០ ខែកញ្ញា ដល់ថ្ងៃទី០១-០២ ខែតុលា

៥-សាលាសង្កាត់បឹងទំពុនរយៈពេល១៣ថ្ងៃ គឺចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី១៥ ខែតុលា។

តមកពីទំព័រទី 10 **ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹង...**

បំណងចង់ដាក់តំណាងរបស់ខ្លួនជាអ្នកសង្កេតការណ៍ដើម្បីពិនិត្យមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់នីមួយៗ អាចសុំចុះឈ្មោះតំណាងគណបក្សនយោបាយនៅក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់ពីថ្ងៃទី២៥ ខែសីហា ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១១។ គណបក្សនយោបាយដែលបានទទួលការអនុញ្ញាតជាផ្លូវការពីក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយនោះ គឺមានសិទ្ធិចូលរួមសង្កេតការណ៍ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១។ ដោយឡែក ដើម្បីសង្កេតមើលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញឆ្នាំ២០១១ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ គណបក្សដែលឈរឈ្មោះបោះឆ្នោតត្រូវបញ្ជូនឈ្មោះតំណាងពេញសិទ្ធ និងបម្រុងរបស់ខ្លួនទៅគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត(សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ) ឬគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត(សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា) និងសុំចុះឈ្មោះភ្នាក់ងារគណបក្សទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់)ទៅតាមប្រតិទិនដែលបានចែកជូនរួចហើយ។

# ទឹកជំនន់ជន់លិចនៅតាមឃុំ សង្កាត់ បង្កឱ្យមានការរំខានដល់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ 2011


សាលាឃុំ ព្រែកតាទែន


សាលាឃុំ សន្លុង


ឃុំ បុសលាវ


សាលាឃុំ កោះចិន


សង្កាត់ សៀមរាប


ឃុំ ព្រះប្រសប់